ព្រឹត្តិបត្រព័ត៌មាន ការប្រែប្រួលអាកាសធាតុ #៧

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

តុលា-ធ្នូ ២០១៦

# គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

## ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខណ្ឌច្បាប់និងវិធានរបស់កម្ពុជា

ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខណ្ឌច្បាប់និងវិធាននានា គឺជាតម្រូវការចាំបាច់ ដើម្បីសម្រួលនិងគាំទ្រដល់ការបង្កើតនិងអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរយៈពេលមធ្យមនិងវែង ជាពិសេសក្នុងវិស័យសំខាន់ៗនៃការអភិវឌ្ឍនិងធនធានដូចជា កសិកម្ម ទឹក ជលផល ព្រៃឈើ សុខភាពសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងទីក្រុង។

កិច្ចប្រឹងប្រែងដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខណ្ឌច្បាប់និងវិធាននានាបានចាប់ផ្តើមនៅឆ្នាំ២០១៣ ដោយមានរបាយការណ៍វាយតម្លៃដើម្បីកំណត់អត្តសញ្ញាណចំណុចចាប់ផ្តើមក្នុងការកែសម្រួលនិងពង្រឹងច្បាប់ដែលមានស្រាប់នៅកម្ពុជា ក៏ដូចជាដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិថ្មីៗដែលជាសេចក្តីព្រាង។ ជាលទ្ធផលរចនាសម្ព័ន្ធស្ថាប័នថ្មីមួយដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា គឺការអនុម័តបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សានេះ កាលពីខែឧសភា ឆ្នាំ២០១៥។ បន្ថែមពីលើការងារប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សា

តទៅទំព័រទី២

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានអនុម័ត




*ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានដឹកនាំប្រតិភូចូលរួមស្រាយបំភ្លឺសេចក្តីព្រាងច្បាប់នៅក្នុងសម័យប្រជុំពេញអង្គលើកទី៩ នៃព្រឹទ្ធសភា នីតិកាលទី៣ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៦*

តាមរយៈកិច្ចចរចានិងការប្តេជ្ញាចិត្តជាអន្តរជាតិក៏ដូចជាបច្ចុប្បន្នភាពនៃព័ត៌មានកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រព័ត៌មានលេខមុន ថ្មីៗនេះកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ហើយបច្ចុប្បន្នបានត្រៀមជាស្រេចដើម្បីដាក់ជូនទៅអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC)។ នេះជាការបង្ហាញឱ្យឃើញពីការប្តេជ្ញារបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុជាមួយសហគមន៍អន្តរជាតិ សំដៅបង្កើនលទ្ធភាពក្នុងការទទួលការគាំទ្រចាំបាច់សម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា។

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាស្ថាប័នបង្គោលនៃUNFCCC បានសម្របសម្រួលក្នុងដំណើរការផ្តល់សច្ចាប័ននេះ ដែលកិច្ចដំណើរការផ្តល់សច្ចាប័ននេះមានជាអាទិ៍៖

តទៅទំព័រទី៣

## មាតិកាព័ត៌មាន

**គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត**
- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខណ្ឌច្បាប់និងវិធានរបស់កម្ពុជា......... ១
- រៀនសូត្រពីការអនុវត្តតាមបែបប្រពៃណីសំដៅពង្រីកចំណេះដឹងភាពធន់នឹងអាកាសធាតុ...... ២
- កម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA) មានការកែលម្អសញ្ញាសំគាល់តាមប្រធានបទ វិស័យ និងអនុវិស័យ ដើម្បីតាមដានហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ........................ ៣

**កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ**
- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានអនុម័ត... ១

**សម្លេងពីមូលដ្ឋាន** ........................................ ៤

**ឯកសារបោះពុម្ពផ្សាយថ្មីៗ**................................. ៦

**ការចេញផ្សាយបន្ទាប់**...................................... ៦

**ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ**................. ៦

**ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ**.................. ៦

## ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិបត្រព័ត៌មាននេះចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍ការងារសំខាន់ៗដែលអនុវត្តដោយអង្គការដៃគូ និងសហគមន៍នានាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ យើងខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាននឹងផ្តល់ជាធាតុចូល ដូចជាការផ្តល់មេរៀនល្អៗ និងករណីសិក្សានានា ដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

## ក្រុមការងាររៀបចំ និងត្រួតពិនិត្យ

ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំ កែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕

# គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

## ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខណ្ឌ ...

*តពីទំព័រទី១*

នេះក៏មានអាណត្តិលើការងារអភិវឌ្ឍន៍បៃតង ជីវៈចម្រុះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផងដែរ ដែលធ្វើឱ្យការដោះស្រាយបញ្ហាអភិវឌ្ឍន៍ប្រកបដោយចីរភាពកាន់តែងាយស្រួលនិងគ្រប់ជ្រុងជ្រោយ។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ(ន.ប.អ.)នៃគ.ជ.អ.ច. ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) កំពុងបង្កើនកិច្ចប្រឹងប្រែង ដើម្បីជានាការបញ្ជ្រាបការប្រែប្រួលអាកាសធាតុជាលក្ខណៈប្រព័ន្ធទៅក្នុងសេចក្តីព្រាងបទដ្ឋានគតិយុត្តិដែលកំពុងស្ថិតក្នុងការកែសម្រួលឬរៀបចំថ្មីដោយក្រសួងស្ថាប័នរដ្ឋ។ ន.ប.អ. ធ្វើការពិនិត្យនិងផ្តល់អនុសាសន៍សំដៅពង្រឹងសេចក្តីព្រាងឬវិសោធនកម្មនោះ និងបានកំណត់ឧបករណ៍ដែលមានស្រាប់ ដូចជា សៀវភៅណែនាំរបស់UNEP ស្តីពីបទដ្ឋានគតិយុត្តិជាតិសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលអាចជួយវិស័យនោះក្នុងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុដោយផ្ទាល់។

បច្ចុប្បន្ន កម្មវិធីCCCA/ន.ប.អ. កំពុងផ្តោតលើក្រមបរិស្ថាន និងយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ (ដែលកំពុងរៀបចំដោយក្រសួងបរិស្ថាន) និងលើការកែសម្រួលច្បាប់ស្តីពីជលផល និងការរៀបចំ


សេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម
ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

វិសោធនកម្មច្បាប់ស្តីពីជលផល២០១៥
ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

THE ENVIRONMENT AND NATURAL RESOURCES CODE OF CAMBODIA DRAFT

ENVIRONMENT AND NATURAL RESOURCES CODE OF CAMBODIA

Seventh Draft (Final) – 31 December 2016

Table of Contents

Book 1 General Provisions ... 2
Title 1 General Provisions ... 2
Title 2 Organisation of Jurisdictional Institutions / Jurisdictional Issues ... 8
Title 3 Public Participation ... 25
Title 4 Access to Environmental Information ... 29
Book 2 Environmental Assessment and Monitoring ... 38
Title 1 Risk Assessment ... 38
Title 2 Strategic Environmental Assessment ... 41
Title 3 Environmental Assessment ... 44
Title 4 Environmental Audits, Monitoring, and Reporting ... 64
Book 3 Environmental Management and Sustainability Mechanisms ... 68
Title 1 Disaster Risk Reduction and Management ... 68
Title 2 Climate Change ... 71
Title 3 Sustainable Consumption and Production ... 77
Title 4 Environmental Land Use Planning and Sustainable Cities ... 85
Title 5 Sustainable Tourism ... 94
Title 6 Sustainable Energy ... 96
Title 7 Responsible Extractive Industries ... 106
Book 4 Sustainable Management of Natural Resources ... 112
Title 1 Biodiversity Conservation Corridors and Protected Areas ... 112
Title 2 Management of Biodiversity Conservation Corridors and Protected Areas ... 116
Title 3 Collaborative Management of Natural Resources ... 141
Title 4 Sustainable Forest Management ... 148
Title 5 Wildlife Protection, Conservation, and Management ... 162
Title 6 Protection of Threatened Plants and Ecosystems ... 194
Title 7 Coastal Zone Management ... 209
Title 8 Sustainable Water Resources Management ... 212
Title 9 Sustainable Fisheries ... 236
Book 5 Cultural Heritage Conservation and Management ... 242
Book 6 Waste and Pollution Management ... 257

*ការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងលិខិតបទដ្ឋានគតិយុត្តិដែលកំពុងកែសម្រួលឬរៀបចំថ្មី ដោយក្រសួងស្ថាប័នរដ្ឋនៃរាជរដ្ឋាភិបាល*

ច្បាប់ថ្មីស្តីពីកសិកម្ម (ដែលកំពុងរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ សេចក្តីព្រាងក្រមបរិស្ថាន និងយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ បច្ចុប្បន្ននេះបានដាក់បញ្ចូលរួចហើយនូវវិធានការនានាដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ អនុសាសន៍របស់ន.ប.អ. ដែលទាក់ទងនឹងវិសោធនកម្មច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ថ្មីស្តីពីកសិកម្ម ក៏បានរៀបចំរួចហើយផងដែរ។

នាអនាគត ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនៃគ.ជ.អ.ច. នឹងដើរតួយ៉ាងសកម្មក្នុងការបញ្ជ្រាបកិច្ចការនេះទៅក្នុងក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិដែលកំពុងស្ថិតក្នុងការរៀបចំ៕

## រៀនសូត្រពីការអនុវត្តតាមបែបប្រពៃណីសំដៅពង្រីកចំណេះដឹងភាពធន់នឹងអាកាសធាតុ

សហគមន៍ខុសៗគ្នានៅទូទាំងប្រទេសកម្ពុជាបានថែរក្សាចំណេះដឹងរួមអំពីទម្លាប់នៃការរស់នៅមូលដ្ឋានប្រចាំថ្ងៃរបស់ពួកគេ។ សហគមន៍ជនជាតិដើមភាគតិចពឹងអាស្រ័យលើធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត ដូច្នេះពួកគេត្រូវតែអាចបន្សាំជាប្រចាំទៅនឹងបញ្ហាដែលបណ្តាលមកពីអាកាសធាតុ និងការប្រែប្រួលបរិស្ថានផ្សេងទៀត។ ជាលទ្ធផល ទម្លាប់អនុវត្តតាមបែបប្រពៃណីបានវិវត្តជាបន្តបន្ទាប់ទៅរកវិធានការដែលអាចយកមកអនុវត្ត ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ដោយមានការគាំទ្រពីគម្រោងបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍(MCRDP) ដែលជាផ្នែកមួយនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ នាយកដ្ឋានប្រែប្រួលអាកាសធាតុបាននិងកំពុងរៀបចំជាប្រព័ន្ធនូវចំណេះដឹងនិងការអនុវត្តបែបប្រពៃណីសម្រាប់ធន់នឹងអាកាសធាតុនៅតាមមូលដ្ឋាន។ គោលបំណងនៃកិច្ចផ្តួចផ្តើមនេះ គឺស្វែងយល់ឱ្យកាន់តែប្រសើរនូវការអនុវត្តបែបប្រពៃណីនៅមូលដ្ឋាន ដែលអាចយកមកប្រើប្រាស់ក្នុងរបៀបនៃគោលនយោបាយ និងកម្មវិធីបន្សាំ។ ក្នុងន័យនេះ អ្នកជំនាញនៃគម្រោងMCRDP និងមន្ត្រីបច្ចេកទេសពីរដ្ឋាភិបាល បានធ្វើការសិក្សានិងចងក្រងជាឯកសារសនូវការអនុវត្តបែបប្រពៃណីក្នុងតំបន់ខុសៗគ្នា ក្នុងវិស័យកសិកម្ម ធនធានទឹក អភិវឌ្ឍន៍ទីក្រុង និងដឹកជញ្ជូន។ គម្រោងMCRDP ក៏បានអំពាវនាវដល់អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា និងវិស័យឯកជន ដើម្បីចែករំលែកទម្លាប់អនុវត្តរបស់ជនជាតិដើម និងជាលក្ខណៈប្រពៃណី ដែលពួកគេបានស្រាវជ្រាវនិងចងក្រងកន្លងមក។

ការអនុវត្តខុសៗគ្នាជាច្រើនត្រូវបានប្រមូលផ្តុំតាមរយៈកិច្ចផ្តួចផ្តើមនេះ។ ឧទាហរណ៍ ៖ ការអភិរក្សព្រៃឫស្សី ការគ្រងទឹកភ្លៀង ទឹកជ្រោះធម្មជាតិដែលគ្រប់គ្រងដោយសហគមន៍ បច្ចេកទេសចិញ្ចឹមសត្វដោយនិរន្តរភាព ការប្រើប្រាស់ពូជស្រូវស្រាលខុសៗគ្នានៅតាមមូលដ្ឋាន និងបច្ចេកទេសសង់ស្តានបែបប្រពៃណី។ ការអនុវត្តបែបប្រពៃណីដែលបានចងក្រង ត្រូវ


*ជនជាតិដើមភាគតិចព្នងក្នុងខេត្តមណ្ឌលគិរី សាងសង់ផ្ទះដោយប្រើប្រាស់ឫស្សីព្រៃ ដែលមានការគ្រប់គ្រងដោយនិរន្តរភាពសំដៅការពារកសិដ្ឋានពីហានិភ័យអាកាសធាតុ*

បានចែករំលែកទៅកាន់អ្នករៀបចំគោលនយោបាយ អ្នករៀបចំផែនការ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ នៅក្នុងសិក្ខាសាលាស្តីពីការឆ្លើយតបរបស់កម្ពុជាទៅនឹងការប្រែប្រួលអាកាសធាតុ ដែលបានធ្វើឡើងនៅខេត្តព្រះសីហនុ ថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹងនេះបានបញ្ជាក់ថា វិធានការបែបប្រពៃណីចំណាយតិច ងាយស្រួលយកមកប្រើប្រាស់ទាំងស្ត្រីនិងបុរស ជាហេតុធ្វើឱ្យការពង្រីកវិធីអនុវត្តន៍នេះកាន់តែងាយស្រួល។ ព្រឹត្តិការណ៍នេះក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការរៀបចំគោលនយោបាយ និងកម្មវិធីនានា ដែលផ្តល់តម្លៃនិងលើកកម្ពស់ការអនុវត្តបែបប្រពៃណី ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីកាន់តែមានសភាពធ្ងន់ធ្ងរ ការអនុវត្តបែបប្រពៃណីតែម្យ៉ាងមិនអាចយកឈ្នះឱនភាពនៃបន្សាំដែលសហគមន៍ប្រឈមនោះឡើយ។ ប៉ុន្តែការរៀនសូត្រពីការអនុវត្តតាមប្រពៃណីទាំងនេះរួមផ្សំជាមួយការស្រាវជ្រាវបែបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថ្មីៗ នឹងបង្កើតឱ្យមានដំណោះស្រាយថ្មីៗ ដើម្បីឆ្លើយតបនឹងការប្រឈមនានានៃការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ៕

## កម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) មានការកែលម្អសញ្ញាសំគាល់តាមប្រធានបទ វិស័យ និងអនុវិស័យ ដើម្បីតាមដានហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ

តាមការប្តេជ្ញាដែលបានធ្វើឡើងនៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ប្រទេសអភិវឌ្ឍន៍មានកាតព្វកិច្ចផ្តល់ថវិកា ១០០ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់ហិរញ្ញប្បទានអាកាសធាតុឱ្យបានមុនឆ្នាំ២០២០។ វត្តមានប្រព័ន្ធគ្រប់គ្រាន់ដើម្បីទាក់ទាញហិរញ្ញវត្ថុអន្តរជាតិតាមបែបប្រកួតប្រជែង គឺជាប្រការសំខាន់សម្រាប់កម្ពុជា។ កិច្ចការនេះរាប់បញ្ចូលទាំងសមត្ថភាពក្នុងការតាមដានហិរញ្ញវត្ថុអាកាសធាតុនិងរាយការណ៍អំពីថវិកាដែលទទួលបាន សមត្ថភាពកំណត់អត្តសញ្ញាណសកម្មភាពទាក់ទងនឹងអាកាសធាតុ ការធានាបាននូវវិធីសាស្ត្រឆ្លាតខាងអាកាសធាតុ និងកៀរគរួមគ្នានូវហិរញ្ញប្បទានអាកាសធាតុប្រកបដោយប្រសិទ្ធភាព។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងគណៈកម្មាធិការស្តារនិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) បានឯកភាពកម្មវិធីការងាររួមមួយដើម្បីកែលម្អ តាមដាន និងកៀរគរហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ការកសាងសមត្ថភាពដៃគូអភិវឌ្ឍនិងបុគ្គលិកបច្ចេកទេសនៃCRDB គឺជាអាទិភាពទីមួយនៃកិច្ចព្រមព្រៀងនេះ។ នៅឆ្នាំ២០១៥ សិក្ខាសាលាបណ្តុះបណ្តាលសម្រាប់មន្ត្រីCRDBនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីវិធីសាស្ត្រតាមដានហិរញ្ញវត្ថុអាកាសធាតុនៅក្នុងកម្រងទិន្នន័យODA ត្រូវបានរៀបចំឡើង។




ទិដ្ឋភាពថ្មីៗនៃកម្រងទិន្នន័យ ODA (http://odacambodia.com/Reports/reports_by_sector.asp)

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនោះ មន្ត្រីCRDB បានកំពុងអនុវត្តវិធីសាស្ត្រនេះក្នុងប្រព័ន្ធកម្រងទិន្នន័យODA ដោយអង្កេតតាមដានលើវិស័យប្រែប្រួលអាកាសធាតុ ការវិនិយោគលើអនុវិស័យ និងការប្រើប្រាស់សញ្ញាសំគាល់បន្ថែមតាមប្រធានបទ ដើម្បីតាមដានការវិនិយោគទាក់ទងការប្រែប្រួលអាកាសធាតុ។ ទិដ្ឋភាពថ្មីនៃកម្រងទិន្នន័យនេះ ជួយឱ្យការតាមដានលំហូរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនៅក្នុងODA ដែលមានស្រាប់ពីប្រភពទ្វេភាគីនិងពហុភាគីកាន់តែប្រសើរ។ នៅឆ្នាំ២០១៦ ការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលជាលើកដំបូងនៅក្នុងរបាយការណ៍កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ដែលបានបង្ហាញថាលំហូរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុតាមរយៈប្រភពអន្តរជាតិ កំពុងតែកើនឡើង៕

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស...

*តពីទំព័រទី១*

- ការប្រែសម្រួលជាភាសាខ្មែរនិងត្រួតពិនិត្យកិច្ចព្រមព្រៀងទីក្រុងប៉ារីស ព្រមទាំងរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ផ្តល់សច្ចាប័ន
- ការបញ្ជូនសេចក្តីព្រាងច្បាប់ទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី និងផ្តល់សេចក្តីបំភ្លឺតាមការស្នើសុំ មុនបញ្ជូនទៅកាន់រដ្ឋសភា
- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (គ.ជ.អ.ច.) បានជួបជាមួយគណៈកម្មការទទួលបន្ទុកកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ដើម្បីផ្តល់សេចក្តីពន្យល់ពិស្តារលើសេចក្តីព្រាងច្បាប់នេះ។ គណៈកម្មការនេះបានឯកភាពលើសេចក្តីព្រាងច្បាប់នេះ និងបានសម្រេចបញ្ជូនទៅកាន់សម័យប្រជុំពេញអង្គនៃរដ្ឋសភា។
- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកឧត្តម សាយ សំអាល់ បានដឹកនាំប្រតិភូ ដើម្បីធ្វើការស្រាយបំភ្លឺអំពីសេចក្តីព្រាងច្បាប់នេះនៅក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភានីតិកាលទី៥។ បន្ទាប់ពីស្តាប់ការស្រាយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល សមាជិកសភាបានបោះឆ្នោតគាំទ្រជាឯកច្ឆ័ន្ទដោយបានអនុម័តឯកភាពលើច្បាប់ស្តីពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកឧត្តម សាយ សំអាល់ បានជួបប្រជុំជាមួយគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាននៃព្រឹទ្ធសភា។ គណៈកម្មការនេះបានឯកភាព និងបានសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅកាន់សម័យប្រជុំពេញអង្គនៃព្រឹទ្ធសភា។



កិច្ចប្រជុំជាមួយគណៈកម្មការនៃព្រឹទ្ធសភាស្តីពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅវិមានព្រឹទ្ធសភា

- ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៦ ឯកឧត្តម សាយ សំអាល់ បានដឹកនាំប្រតិភូ ដើម្បីធ្វើការស្រាយបំភ្លឺអំពីសេចក្តីព្រាងច្បាប់នេះនៅក្នុងសម័យប្រជុំពេញអង្គលើកទី៩ នៃព្រឹទ្ធសភានីតិកាលទី៣។ ជាលទ្ធផលព្រឹទ្ធសភាបានបោះឆ្នោតអនុម័តឯកភាព។
- ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្តលេខាលើកិច្ចព្រមព្រៀងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។

បច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងរៀបចំលិខិតុបករណ៍សម្រាប់ការសុំចូលជាសមាជិកនៃកិច្ចព្រមព្រៀងប៉ារីស ដើម្បីដាក់ជូនទៅUNFCCC ដែលជាជំហានចុងក្រោយនៃដំណើរការផ្តល់សច្ចាប័ននេះ៕

# សម្លេងពីមូលដ្ឋាន

## ភាពជាដៃគូពហុអ្នកពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ

រាជធានីភ្នំពេញត្រូវការជាបន្ទាន់នូវដំណោះស្រាយគ្រប់គ្រងសំណល់ឱ្យស្របនឹងជំហានយ៉ាងឆាប់រហ័សនៃការពង្រីកទីក្រុង និងការអភិវឌ្ឍសេដ្ឋកិច្ច។ ទម្លាប់នៃការគ្រប់គ្រងសំណល់ដែលគ្មាននិរន្តរភាពបង្កផលប៉ះពាល់អវិជ្ជមានមកលើទឹក ដី និងនាំមកនូវហានិភ័យធ្ងន់ធ្ងរចំពោះសុខភាពសាធារណៈ។ មេតានជាឧស្ម័នផ្ទះកញ្ចក់ដែលមានឥទ្ធិពលខ្ពស់ ភាយចេញពីទីលានចាក់សំរាម និងជាកត្តារួមចំណែកយ៉ាងសំខាន់ដល់ការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ ការបំភាយមេតានពីទីលានចាក់សំរាមនៅទីក្រុងធំៗទាំងបួននៃប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានកម្រិតខ្ពស់ដល់ ៣៦០ ០០០តោនសមមូលឧស្ម័នកាបូនិក ក្នុងមួយឆ្នាំ និងដើរតួចម្បងក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបនៅកម្ពុជា។

អង្គការណិចស៊ុសសម្រាប់អភិវឌ្ឍន៍(Nexus for Development) ដែលជាអង្គការបណ្តាញនិរន្តរភាពមានទីតាំងនៅភ្នំពេញ បានបង្កើតភាពជាដៃគូជាមួយកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP)និងវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក(IGES) ក្នុងការកោះប្រជុំអ្នកពាក់ព័ន្ធលើការងារទីក្រុងដើម្បីបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ថ្មីមួយសម្រាប់ភ្នំពេញ។ គម្រោងនេះនឹងធ្វើការដោះស្រាយនិងកាត់បន្ថយហានិភ័យធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុដែលទាក់ទងនឹងការបញ្ចេញឧស្ម័នពីទីលានចាក់សំរាម ព្រមទាំងគ្រប់គ្រងសំណល់ដែលគ្មាននិរន្តរភាព ដោយចាត់ជាអាទិភាពនូវទម្លាប់គ្រប់គ្រងទីលានចាក់សំរាមឱ្យបានសមស្រប ទប់ស្កាត់ការបង្កើតសំណល់ បង្កើនការប្រើប្រាស់ឡើងវិញ កែច្នៃ និងច្នៃប្រឌិតបច្ចេកវិទ្យាប្រែក្លាយសំណល់



*លោក លឹម វិចិត្រ នាយករងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ ថ្លែងសុន្ទរកថាបើកសិក្ខាសាលាចាប់ផ្តើមគម្រោង ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ សណ្ឋាគារកាំបូឌីយ៉ាណា*

ទៅជាថាមពល។

លទ្ធផលរំពឹងទុកនៃគម្រោងនេះគឺ ការបន្សុីជាមួយចក្ខុវិស័យដើម្បីសម្រេចបាននូវការអភិវឌ្ឍឆ្លាតខាងអាកាសធាតុ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ ការអនុវត្តគម្រោងនេះ ក៏ត្រូវអនុវត្តសកម្មភាពដូចមានចែងក្នុងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនិងផែនការយុទ្ធសាស្ត្រទីក្រុងភ្នំពេញបៃតងផងដែរ ដែលក្នុងនោះរួមមាន៖

- ការគូសបញ្ជាក់ពីបញ្ហាប្រឈមចម្បងៗ និងជំរុញការរៀបចំផែនការ និងបច្ចេកវិទ្យាកាបូនទាបគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព
- ការវិភាគអំពីការកាត់បន្ថយការបញ្ចេញឧស្ម័ននិងសក្តានុពលកាត់បន្ថយ ដែលនឹងជម្រុញឱ្យមានការផ្ទេរបច្ចេកវិទ្យាសមស្របសម្រាប់ការអភិវឌ្ឍបញ្ចេញកាបូនទាប។ គម្រោងនេះក៏នឹងជំរុញការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងបញ្ចេញកាបូនទាប និងបង្កើតយន្តការសម្របសម្រួលនៅកម្រិតទីក្រុងផងដែរ។
- ការបន្សុីជាមួយផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ២០១៦-២០១៨ ដែលគូសបញ្ជាក់ពីការគ្រប់គ្រងសំណល់រឹងនៅទីក្រុង ទីប្រជុំជន និងទីរួមខេត្ត ដែលជាអាទិភាពនៃយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ប្រកបដោយចីរភាព។

សិក្ខាសាលាចាប់ផ្តើមគម្រោង ដែលដឹកនាំដោយសាលារាជធានីភ្នំពេញ ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានរៀបចំថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ដោយមានតំណាងចូលរួមប្រមាណ៦០នាក់ អញ្ជើញមកពីរដ្ឋាភិបាលថ្នាក់ជាតិនិងមូលដ្ឋាន គ្រឹះស្ថានឧត្តមសិក្សា និងប្រតិបត្តិករក្នុងវិស័យអភិវឌ្ឍន៍។ បច្ចុប្បន្ន មន្ត្រីរដ្ឋបាលសាធារណៈនិងមន្ត្រីបច្ចេកទេសនៃរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ បានដើរតួយ៉ាងសកម្មនៅក្នុងការបង្កើតដំណោះស្រាយសមស្របតាមបរិបទ ដើម្បីកែលម្អទម្លាប់នៃការគ្រប់គ្រងសំណល់។

កិច្ចប្រជុំចាប់ផ្តើមមួយនៅកម្រិតទីក្រុង បានធ្វើឡើងរួចមកហើយនៅសាលារាជធានីភ្នំពេញ នាសប្តាហ៍ចុងក្រោយនៃខែធ្នូកន្លងទៅនេះ ដោយមានការចូលរួមពីអភិបាលរងខណ្ឌចំនួន១២ និងតំណាងនាយកដ្ឋាននៃក្រសួងពាក់ព័ន្ធ។ ការពិគ្រោះយោបល់បន្ថែម នឹងគ្រោងធ្វើឡើងរហូតដល់ខែឧសភា ឆ្នាំ២០១៧។ លទ្ធផលសំខាន់ៗនៃកិច្ចពិគ្រោះយោបល់ទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងខ្លឹមសារនៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ ដើម្បីឆ្លុះបញ្ចាំងសមត្ថភាពនាពេលបច្ចុប្បន្ន៕ *(អត្ថបទដោយ ណិចស៊ុសកាបូនសម្រាប់អភិវឌ្ឍន៍ http://nexusfordevelopment.org/ )*

## បច្ចេកទេសកសិកម្មថ្មីនាំឱ្យកសិករមានជីវភាពប្រសើរជាងមុន

លោក ស្រី ស៊ីថា អាយុ៥២ឆ្នាំ និងភរិយា លោកស្រី ហុង លឹមហួរ និងកូនទាំងបួននាក់រស់នៅក្នុងភូមិរំដេង ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ពួកគេដាំបន្លែជាមុខរបរបឋមនិងធ្វើស្រែប្រាំងតាមរដូវលើដីដួលជាប្រភពប្រាក់ចំណូលបន្ទាប់បន្សំ។ រយៈពេលជាច្រើនឆ្នាំមកនេះ គ្រួសារលោក ស្រី ស៊ីថា មិនបានទទួលផលចំណេញពីដំណាំកសិកម្មឡើយ ដោយសារការប្រឈមកាន់តែច្រើនពីគ្រោះមហន្តរាយធាតុអាកាស ដូចជា កំណើនសីតុណ្ហភាព និងគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង។

នៅឆ្នាំ២០១៤ លោក ស៊ីថា បានឃើញឱកាសមួយនៅពេលដែលអង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍(AFD) ក្រោមគម្រោងហារវែសកម្ពុជា ដែលទទួលមូលនិធិពីUSAID បានចូលមកក្នុងភូមិនេះ។ ពួកគេបាននាំមកជាមួយនូវបច្ចេកទេសកសិកម្មបែបថ្មី ដើម្បីបង្កើនសមត្ថភាពបន្សុំារបស់កសិករក្នុងមូលដ្ឋាន ហើយលោក ស៊ីថា បានសម្រេចចូលរួមនៅក្នុងការសាកល្បងបច្ចេកទេសទាំងនេះ។

គាត់បានអនុវត្តតាមគ្រប់គោលការណ៍ដែលអ្នកជំនាញកសិកម្មបានណែនាំ ដូចជា ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក និងការគ្របដំណាំដោយកម្រាលប្លាស្ទិក ហើយបច្ចុប្បន្ននេះ គាត់គឺជាកសិករគំរូម្នាក់។ ជារួម

គាត់បានគ្រប់គ្រងដំណាំបីលើករួចមកហើយ ដោយប្រើប្រាស់បច្ចេកវិទ្យាបន្សាំដែលបានរៀនសូត្រ ហើយឃើញថាផលចំណេញកើនឡើងមែន។ គាត់បានពោលថា បច្ចេកទេសកសិកម្មថ្មីបន្សាំនឹងអាកាសធាតុ បាននាំមកនូវក្តីសង្ឃឹមសម្រាប់គ្រួសារគាត់ និងកសិករដទៃទៀតនៅក្នុងភូមិអូររំដេង។

ជាមួយផ្ទៃដីទំហំ ៤ ០០០ម² នៅក្នុងជុំដំបូងនៃការដាំដំណាំរបស់គាត់ លោក ស៊ីថា បានដាំឪឡឹកនៅលើទំហំដីជាងពាក់កណ្តាល និងពាក់កណ្តាលទៀតដាំសណ្តែកកួរ ដោយរក្សាទំហំរង កម្ពស់ និងចន្លោះរង តាមការណែនាំរបស់អ្នកឯកទេស (សម្រាប់សណ្តែកកួរ ទំហំរង១,៥ម កម្ពស់រង០,២៥-០,៣០ម និងចន្លោះរង០,៣០-០,៣៥ម ចំណែកឪឡឹក ទំហំរង១,៥ម កម្ពស់រង០,២៥-០,៣០ម និងចន្លោះរង០,៦០ម)។ គាត់ក៏បានប្រើប្រាស់គម្របប្លាស្ទិក ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក និងទ្រើងសំណាញ់តាមការណែនាំរបស់អ្នកឯកទេសផងដែរ។ លោក ស៊ីថា កត់សម្គាល់ថា "កាលពីមុន ខ្ញុំត្រូវចូលព្រៃដើម្បីកាប់កូនឈើសម្រាប់ធ្វើជន្លង់។ ការធ្វើបែបនេះចំណាយពេលច្រើន និងជាកិច្ចការដែលបំផ្លាញបរិស្ថាន។ ការតម្លើងគម្របប្លាស្ទិកនិងប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក បានកាត់បន្ថយបន្ទុកការងាររបស់ខ្ញុំ ជាពិសេស ពុំចាំបាច់បោចស្មៅច្រើនដូចមុនឡើយ។" ពីខែមករាដល់មេសា ឆ្នាំ២០១៦ សីតុណ្ហភាពឡើងខ្ពស់ខ្លាំងនៅភូមិអូររំដេង និងបានធ្វើឱ្យអណ្តូងភាគច្រើនរីងស្ងួត។ កសិករដទៃទៀតនិងលោកស៊ីថា បារម្ភអំពីភាពរាំងស្ងួតនេះ ប៉ុន្តែប្រព័ន្ធស្រោចស្រពដោយតំណក់ទឹករបស់គាត់ និងបច្ចេកទេសដទៃទៀតដែលគាត់បានប្រើប្រាស់សម្រាប់ដំណាំបន្លែ នៅតែផ្តល់ផលច្រើន និងចំណេញច្រើន ប្រមាណ៦៥២ដុល្លាអាមេរិក។


ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹកនិងគម្របផ្លាស្ទិកនៅក្នុងចំការត្រឡាច ឆ្នាំ ២០១៦


លោក ស៊ីថា បានទទួលទិន្នផលដំណាំម្រះដោយសារតែប្រព័ន្ធស្រោចស្រពដោយតំណក់ទឹកនិងគម្របផ្លាស្ទិក ឆ្នាំ ២០១៦

នៅជុំទីពីរ លោកស៊ីថា បានដាំម្រះ លើទំហំដី ២ ០០០ម² និងត្រសក់លើដីទំហំ ១ ០០០ម²។ បច្ចេកទេសនេះ គឺទុកចន្លោះរងខុសគ្នាបន្តិច ០,៦០មសម្រាប់ម្រះ និង ០,២៥មសម្រាប់ត្រសក់ ប៉ុន្តែនៅតែបន្តប្រើប្រាស់ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក និងគម្របប្លាស្ទិក។ គាត់អាចបង្កើនផលិតភាពដំណាំ និងបានទទួលផលចំណេញ ១ ២៣៣ដុល្លា។

ទោះជាការគាំទ្របច្ចេកទេសពីគម្រោងនេះបានបញ្ចប់ហើយក៏ដោយ ក៏ឥឡូវនេះលោកស៊ីថា មានទំនុកចិត្តថា គាត់អាចបន្តប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាំងនេះ ដើម្បីពង្រីកដីដាំដំណាំនិងបង្កើនផលិតភាពចំការរបស់គាត់។ គាត់ក៏មានបំណងចែករំលែកចំណេះដឹងរបស់ខ្លួនទៅអ្នកភូមិដទៃផងដែរ។ ប្រការសំខាន់នោះគឺ គាត់បានឈប់ជួលដីសម្រាប់ធ្វើស្រែប្រាំងទៀតហើយ ដោយសារតែដំណាំបន្លែរបស់គាត់ផ្តល់ផលចំណេញកាន់តែច្រើន ហើយឥឡូវនេះគ្រួសាររបស់គាត់មានពេលសម្រាប់នៅជាមួយគ្នាកាន់តែច្រើននៅក្នុងភូមិនេះ៕ *(អត្ថបទដោយអង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ ហៅកាត់ថា AFD តាមរយៈវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា)*

## បន្សាំកំពុងអនុវត្ត៖ ការកែលម្អការផ្គត់ផ្គង់ទឹកក្នុងសហគមន៍តំបន់ការពារធម្មជាតិជប់តាសុក

អ្នកភូមិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិជប់តាសុក ដែលស្ថិតនៅក្នុងឧទ្យានជាតិភ្នំគូលេន ខេត្តសៀមរាប កំពុងប្រឈមការលំបាកមួយចំនួនក្នុងការកែលម្អផលិតភាពកសិកម្មដោយសារកង្វះទឹក។ បច្ចុប្បន្ន ពួកគេមិនអាចដាំដំណាំនៅក្នុងរដូវណាមួយបានឡើយ បើទោះជាស្រូវលើទីទួលស្វាយចន្ទី ត្រាវឆ្លាស់ជាមួយចេក ម្នាស់ ស្វាយ និងគូលេន។ ជាការរំពឹងទុកទៅថ្ងៃអនាគត ការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់ផលិតកម្មកសិកម្មកាន់តែធ្ងន់ធ្ងរ ហើយនឹងក្លាយជាក្តីកង្វល់របស់សហគមន៍កាន់តែខ្លាំងឡើង។

គម្រោង ជំរុញភាពធន់របស់សហគមន៍ជនបទរស់ក្នុងតំបន់ការពារធម្មជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលអនុវត្តដោយក្រសួងបរិស្ថាននិងគាំទ្រមូលនិធិពីUNEP កំពុងធ្វើការជាមួយអ្នកភូមិ ដើម្បីស្វែងយល់ពីរបៀបដែលពួកគេអាចត្រៀមខ្លួនបានកាន់តែប្រសើរដើម្បីទប់នឹងហានិភ័យអាកាសធាតុទាំងបច្ចុប្បន្ននិងនាពេលអនាគត។ វិធានការនានាដែលបានអនុវត្ត មានជាអាទិ៍៖

- ការកំណត់អត្តសញ្ញាណហានិភ័យទាក់ទងនឹងអាកាសធាតុនិងផលប៉ះពាល់ដែលអាចកើតមាន
- ការកំណត់ភាពងាយរងគ្រោះសំខាន់ៗនៃក្រុមប្រជាជនដែលរងផលប៉ះពាល់ពីហានិភ័យទាក់ទងនឹងអាកាសធាតុ
- ការវិភាគព័ត៌មានស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើរបរចិញ្ចឹមជីវិត។

គម្រោងនេះក៏បានកំណត់អត្តសញ្ញាណយុទ្ធសាស្ត្របន្សាំកម្រិតគ្រួសារក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប៉ះទង្គិចនិងវិបត្តិទាក់ទងអាកាសធាតុ។ ការវិភាគមួយចំនួនកំពុងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពអាទិភាពចំពោះមុខសម្រាប់សហគមន៍។

អន្តរាគមន៍បន្សាំដែលបានរកឃើញសម្រាប់ពង្រឹងភាពធន់នឹងអាកាសធាតុ ដែលគាំទ្រដោយគម្រោងនេះមានជាអាទិ៍៖

- ការសាងសង់អាងស្តុកទឹក (ការសង់ទំនប់នៅជុំវិញអាងទទួលទឹកភ្លៀង) ចំនួន៨កន្លែង នៅក្នុងភូមិ
- ការសាងសង់បណ្តាញចែកចាយទឹកប្រវែង ២ ០០០ម ដែលបានជួយដល់គ្រួសារគោលដៅក្នុងការទទួលបានទឹកស្អាតប្រសើរជាងមុន ជាពិសេសសម្រាប់ច្បារដំណាំនិងការចិញ្ចឹមសត្វ

*តទៅទំព័រទី៦*

## បន្សាំកំពុងអនុវត្តៈ ការកែលម្អការផ្គត់ផ្គង់ទឹកក្នុងសហគមន៍តំបន់...

*តពីទំព័រទី៥*

- ការបង្កើតគណៈកម្មការគ្រប់គ្រងទឹក ការអភិវឌ្ឍសមត្ថភាពគណៈកម្មការ និងបង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់ទឹក ដើម្បីអាចឱ្យទាំងគណៈកម្មការគ្រប់គ្រងទឹកនិងអ្នកប្រើប្រាស់ទឹកគ្រប់គ្រងទឹកបានកាន់តែមានប្រសិទ្ធភាព។
- អន្តរាគមន៍ផ្សេងៗទៀតពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដូចជាការបង្កើតថ្នាលបណ្ដុះកូនឈើ សកម្មភាពដាំព្រៃឈើឡើងវិញ និងការចិញ្ចឹមសត្វ ដើម្បីបង្កើនភាពធន់នៅក្នុងសហគមន៍ និងលើកកម្ពស់ការអភិរក្សធនធានធម្មជាតិផងដែរ។

អ្នកភូមិដែលរួមទាំងប្រធានគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ប្រធានភូមិ និងមេគ្រួសារ បានសង្កត់ធ្ងន់ថា ប្រព័ន្ធផ្គត់ផ្គង់ទឹកបានជួយអ្នកភូមិ និងសមាជិកសហគមន៍យ៉ាងច្រើនក្នុងការទទួលបានទឹកស្អាតច្រើនជាងមុនសម្រាប់សន្តិសុខស្បៀងនៅរដូវប្រាំង។ បច្ចុប្បន្ន ប្រជាជនប្រមាណ៥០គ្រួសារ កំពុងប្រើប្រាស់ទឹកពីប្រព័ន្ធផ្គត់ផ្គង់នេះ។ *(ប្រភពពី មូលនិធិបន្សាំនៅកម្ពុជា៖* https://www.adaptation-fund.org/project/enhancing-climate-resilience-of-rural-communities-living-in-protected-areas-of-cambodia/ *)*



*ការសាងសង់អណ្ដូងស្នប់ក្នុងសហគមន៍នៅឆ្នាំ២០១៥ និងការថែទាំជាប្រចាំពីសំណាក់សហគមន៍*

## ការចេញផ្សាយបន្ទាប់...

### ជំនួយឥតសំណងការប្រែប្រួលអាកាសធាតុកំពុងជួយស្វែងរកវិធីថ្មីដើម្បីកសាងសមត្ថភាពបន្សាំ



មូលនិធិជំនួយឥតសំណងប្រមាណ៤,២លានដុល្លាអាមេរិក ត្រូវបានផ្ដល់តាមរយៈមូលនិធិជំនួយឥតសំណងរបស់កម្មវិធីCCCA ទៅកាន់ក្រសួងស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានស្រាវជ្រាវ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលមានចំណាប់អារម្មណ៍លើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ មូលនិធិនេះបានបង្កើតឱកាសចំនួន៣ប្រភេទផ្សេងគ្នាសម្រាប់អន្តរាគមន៍នឹងការប្រែប្រួលអាកាសធាតុ។ នៅលេខបន្ទាប់ លោកអ្នកនឹងស្វែងយល់អំពីគម្រោងជំនួយឥតសំណងដែលកំពុងអនុវត្ត និងការសម្ភាសជាមួយអ្នកទទួលផលពីមូលនិធិនេះ នៅលើមាគ៌ាថ្មីមួយដើម្បីកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ

### សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ




នាយកដ្ឋានប្រែប្រួលអាកាសធាតុ នឹងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសទ្ទានុក្រមការប្រែប្រួលអាកាសធាតុ ដែលមានបច្ចេកសព្ទសរុបចំនួន ៤៦៣ពាក្យ អមដោយនិយមន័យ ក្នុងត្រីមាសទី១ ឆ្នាំ២០១៧។ ឯកសារនេះចែងអំពីស្តង់ដារបច្ចេកសព្ទដែលត្រូវប្រើប្រាស់ក្នុងវិស័យប្រែប្រួលអាកាសធាតុប្រកបដោយសង្គតិភាព សុក្រឹតភាព និងឯកភាពតាមក្បួនភាសាខ្មែរ។ អ្នកជំនាញផ្នែកការប្រែប្រួលអាកាសធាតុរួមជាមួយក្រុមប្រឹក្សាជាតិភាសាខ្មែរ បានជួបប្រជុំចំនួន៧១លើក ដើម្បីពិនិត្យបច្ចេកសព្ទសរុបចំនួន៤៦៣ពាក្យ ដោយប្រើរយៈពេលជាង១០ខែ ផ្អែកលើស្តង់ដារភាសាខ្មែរ ទិដ្ឋភាពបច្ចេកទេស និងការអនុវត្តជាក់ស្តែង។ សទ្ទានុក្រមនេះនឹងមាននៅក្នុងគេហទំព័រ www.camclimate.org.kh។

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

មករា វគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញអំពីគោលការណ៍ណែនាំអនុវត្តជំនួយឥតសំណងពីកម្មវិធី CCCA

មករា-កុម្ភៈ ការសិក្សាលទ្ធភាពស្ដីពីការវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សាំ ការវាយតម្លៃផលប៉ះពាល់បរិស្ថានដំបូង និងការរៀបចំគម្រោងក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ ព្រៃវែង និងត្បូងឃ្មុំ

កុម្ភៈ កិច្ចប្រជុំបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ

កុម្ភៈ កិច្ចប្រជុំលើកទី១១នៃក្រុមប្រឹក្សាភិបាលកម្មវិធី CCCA

មីនា សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងលទ្ធផលសិក្សាវិធានការឆ្លើយតបនឹងអាកាសធាតុនិងផែនការ ឆ្នាំ២០១៨ សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ

មីនា ពិធីប្រកាសដាក់ឱ្យប្រើប្រាស់សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, SWEDEN

**អាសយដ្ឋានទាក់ទង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ៦៣៣ ៨៣៧០ | សារអេឡិចត្រូនិច៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh